# ទស្សនវិស័យមុខរបរ និងការងារ



## តម្រូវការជំនាញ និងការងារសម្រាប់យុវជន

លេខ២ ឆមាសទី២ ឆ្នាំ២០២៤

រៀបចំ និងបោះពុម្ពផ្សាយដោយ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# អារម្ភកថា

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពធន់ និងចីរភាព តាមរយៈការដាក់ចេញ និងការអនុវត្តប្រកបដោយបុរេសកម្មនូវគោលនយោបាយទីផ្សារការងារសកម្ម ដើម្បីបង្កើត រក្សា និងបង្កើនការងារជូនប្រជាជន ពិសេសយុវជន កម្មករនិយោជិត ទាំងក្នុង និងក្រៅប្រព័ន្ធ។ ការរៀបចំ និងធ្វើបច្ចុប្បន្នភាពព័ត៌មានទីផ្សារការងារជាប្រចាំ និងទៀងទាត់ ជាកិច្ចការសំខាន់មួយនៃការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម។ ក្នុងន័យនេះ កាលពីដើមឆ្នាំ២០២៤ កន្លងទៅ ក្រសួងបានចាប់ផ្តើមរៀបចំ និងផ្សព្វផ្សាយជាលើកដំបូងនូវព្រឹត្តិបត្រព័ត៌មានទីផ្សារការងារស្តីពីទស្សនវិស័យសេដ្ឋកិច្ចទីផ្សារការងារកម្ពុជា សម្រាប់ឆមាសទី១ ឆ្នាំ២០២៤។

ក្នុងឆមាសទី២នេះ ក្រសួងបានបន្តរៀបចំ និងផ្សព្វផ្សាយនូវព្រឹត្តិបត្រព័ត៌មានទីផ្សារការងារលេខ២ ឆមាសទី២ ឆ្នាំ២០២៤ **ស្តីពី «ទស្សនវិស័យមុខរបរ និងការងារ»** ដែលជាត្រីវិស័យសម្រាប់បង្ហាញផ្លូវក្នុងការស្វែងរកជំនាញ និងការងារដែលមានតម្រូវការច្រើនទៅតាមវិស័យការងារដែលកំពុងរីកចម្រើន ព្រមទាំងដើរតួជាមគ្គុទ្ទេសក៍សម្រាប់ទំនាក់ទំនងក្នុងការសិក្សា និងជម្រើសអាជីព។ ព្រឹត្តិបត្រព័ត៌មាននេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្តល់ព័ត៌មាន និងការយល់ដឹងអំពីទីផ្សារការងារ មុខរបរ និងតម្រូវការជំនាញ ព្រមទាំងបង្កើតបរិយាកាសងាយស្រួលដល់សិស្ស-និស្សិត កម្មករនិយោជិត និងអ្នកដែលកំពុងស្វែងរកការងារឱ្យរៀបចំផែនការអាជីពរបស់ខ្លួន និងជ្រើសរើសជំនាញដែលស្របតាមតម្រូវការទីផ្សារការងារបច្ចុប្បន្ន ដើម្បីទទួលបានប្រាក់ចំណូលខ្ពស់ និងអភិវឌ្ឍខ្លួនសម្រាប់ទីផ្សារការងារនៅថ្ងៃអនាគត។ ព្រឹត្តិបត្រព័ត៌មាននេះ ផ្សារភ្ជាប់ជាមួយចំណេះដឹង និងព័ត៌មាន ដែលសិស្ស-និស្សិត កម្មករនិយោជិត និងអ្នកកំពុងស្វែងរកការងារ អាចជ្រើសរើសជំនាញសិក្សា ក៏ដូចជាការងារដែលមានតម្រូវការខ្ពស់នៅតាមវិស័យនានា ប្រកបដោយទំនុកចិត្ត ស្របតាមចំណង់ចំណូលចិត្ត និងអាចផ្តល់នូវជំនាញដែលមានតម្លៃ និងតម្រូវការខ្ពស់។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នឹងបន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពព្រឹត្តិបត្រព័ត៌មានទីផ្សារការងារនេះឱ្យកាន់តែល្អប្រសើរ និងគ្រប់ជ្រុងជ្រោយ ហើយសង្ឃឹមថាព្រឹត្តិបត្រព័ត៌មាននេះ នឹងក្លាយទៅជាឯកសារយោងមួយយ៉ាងសំខាន់សម្រាប់យុវជន សិស្ស-និស្សិត កម្មករនិយោជិត និយោជក អ្នកផ្តល់ការអប់រំនិងបណ្តុះបណ្តាល អ្នកគ្រប់គ្រងបុគ្គលិក អ្នកសិក្សាស្រាវជ្រាវ និងអ្នករៀបចំគោលនយោបាយ ដើម្បីរៀបចំផែនការសិក្សានិងអាជីព រៀបចំវគ្គបណ្តុះបណ្តាលឱ្យស្របនឹងតម្រូវការទីផ្សារការងារ គ្រប់គ្រងបុគ្គលិកឱ្យមានប្រសិទ្ធភាពនិងផលិតភាពខ្ពស់ និងផ្តល់ជាតុចូលដើម្បីរៀបចំគោលនយោបាយទីផ្សារការងារសកម្មសំដៅចូលរួមចំណែកក្នុងការបង្កើត ការរក្សា និងការបង្កើនការងារឱ្យកាន់តែច្រើន ទាំងបរិមាណ និងគុណភាពជូនប្រជាពលរដ្ឋ។

ថ្ងៃចន្ទ ៥កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី៧ ខែតុលា ឆ្នាំ២០២៤
**រដ្ឋមន្ត្រី**

**ហេង សួរ**

# មាតិកា

ព្រឹត្តិបត្រព័ត៌មានទីផ្សារការងារនេះ បែងចែកមាតិកាជា ៥ផ្នែកសំខាន់ៗ ដូចជា៖ ផ្នែកទី១ ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារការងារប្រទេសកម្ពុជា, ផ្នែកទី២ ការព្យាករនៃតម្រូវការការងារនៅកម្ពុជាក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម, ផ្នែកទី៣ តម្រូវការមុខរបរក្នុងទីផ្សារការងារតាមកម្រិតនៃជំនាញ និងមុខតំណែង, ផ្នែកទី៤ មុខរបរមានតម្រូវការខ្ពស់ទាំង២០ សម្រាប់យុវជន ដែលស្វែងរកការងារដំបូង និងផ្នែកទី៥ ការចាប់យកឱកាសបណ្តុះបណ្តាល និងប្រឹក្សាយោបល់ការងារ។




## ផ្នែកទី១៖ ស្ថានភាពសេដ្ឋកិច្ច និងទីផ្សារការងារប្រទេសកម្ពុជា

### ក. ស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា

សេដ្ឋកិច្ចកម្ពុជាបានបង្ហាញពីស្ថានភាពប្រសើរឡើងវិញ ដោយរំពឹងថានឹងមានកំណើនក្នុងអត្រា ៦% ក្នុងឆ្នាំ២០២៤ និង ៦,៣% ក្នុងឆ្នាំ២០២៥ ដោយផ្អែកតាមការព្យាកររបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ការព្យាករនេះ ក៏ស្របគ្នាជាមួយនឹងស្ថាប័នអន្តរជាតិធំៗដូចជា ធនាគារពិភពលោក (WB), ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)។ កំណើននេះ បានមកពីកត្តាជំរុញ និងការគាំទ្រមួយចំនួនដូចជា ការងើបឡើងវិញនៃច្រវ៉ាក់ផលិតកម្ម និងនិន្នាការវិជ្ជមាននៃអនុវិស័យក្រៅកាត់ដេរ និងការដាក់ចេញវិធានការមានប្រសិទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទាញវិនិយោគិនពីបរទេស។

**រូបភាពទី១៖** ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) ឆ្នាំ២០១៧ ដល់ឆ្នាំ២០២៥



កំណើនសេដ្ឋកិច្ចកម្ពុជាមានសន្ទុះងើបឡើងវិញ ក៏ដោយសារតម្រូវការ ឬការបញ្ជាទិញពី សហរដ្ឋអាមេរិក សហភាពអឺរ៉ុប និងប្រទេសចិន ដែលជាគោលដៅទីផ្សារនាំចេញចម្បងៗរបស់កម្ពុជា។ ការបញ្ជាទិញនេះមានសន្ទុះ ក៏ព្រោះតែសេដ្ឋកិច្ចសហរដ្ឋអាមេរិកត្រូវបានព្យាករថាមានកំណើនជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ២% ក្នុងចន្លោះឆ្នាំ២០២៤ ដល់ឆ្នាំ២០២៧ ដែលជំរុញឱ្យមានការវិលមករកប្រក្រតីភាពនៃការចំណាយ និងតម្រូវការក្នុងទីផ្សារសហរដ្ឋអាមេរិក ខណៈកំណើនសេដ្ឋកិច្ចជាមធ្យមប្រចាំឆ្នាំរបស់សហភាពអឺរ៉ុប ស្ថិតក្នុងរង្វង់ ១,៣% និងសេដ្ឋកិច្ចប្រទេសចិនមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំក្នុងរង្វង់ ៤% ក្នុងចន្លោះឆ្នាំដូចគ្នានេះ។ សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាពឹងផ្អែកទៅលើវិស័យចម្បងៗចំនួន ៣ ពោលគឺ សេវាកម្ម ឧស្សាហកម្ម និងកសិកម្ម។ ដោយឡែក វិស័យកសិកម្មមានកំណើនទាបក្នុងឆ្នាំ២០២០ ប៉ុន្តែវិស័យនេះត្រូវបានព្យាករថាងើបឡើងវិញ ក្នុងអត្រាកំណើនប្រមាណ ០,៧% ក្នុងឆ្នាំ២០២៤ និង ១,១% នៅឆ្នាំ២០២៥ នេះ។

**រូបភាពទី២៖** កំណើនផ.ស.ស. និងការងារតាមវិស័យ (ឆ្នាំ២០២៤-២០២៥)

| | **សេវាកម្ម** | | **ឧស្សាហកម្ម** | | **កសិកម្ម** | | **សរុប** | |
|---|---|---|---|---|---|---|---|---|
| | 2024 | 2025 | 2024 | 2025 | 2024 | 2025 | 2024 | 2025 |
| កំណើនផ.ស.ស. | ↑5.8% | ↑5.6% | ↑7.9% | ↑8.6% | ↑0.7% | ↑1.1% | ↑6.0% | ↑6.3% |
| អត្រាកំណើនការងារ | ↑3.1% | ↑4.6% | ↑1.9% | ↑2.6% | ↓3.5% | ↓3.6% | ↑0.9% | ↑1.8% |
| កំណើនចំនួនការងារ(នាក់) | ↑137,551 | ↑208,421 | ↑49,396 | ↑69,229 | ↓99,191 | ↓100,609 | ↑87,756 | ↑177,040 |
| ចំនួនការងារសរុប(នាក់) | 4.5 លាន | 4.7 លាន | 2.6 លាន | 2.7 លាន | 2.8 លាន | 2.7 លាន | 9.9 លាន | 10.1 លាន |

ប្រភព៖ ការព្យាកររបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

វិស័យឧស្សាហកម្ម បានធ្លាក់ចុះខ្លាំងក្នុងឆ្នាំ២០២០ ដោយសារវិបត្តិកូវីដ-១៩ ប៉ុន្តែបង្ហាញពីការងើបឡើងវិញយ៉ាងឆាប់រហ័សសម្រាប់ឆ្នាំបន្តបន្ទាប់។ ជាក់ស្តែង វិស័យឧស្សាហកម្មត្រូវបានព្យាករថា មានកំណើន ៧,៩% ក្នុងឆ្នាំ២០២៤ និងនឹងបន្តកើនដល់ ៨,៦% នៅឆ្នាំ២០២៥ ។ ការងើបឡើងវិញនៃវិស័យនេះ គឺមានការគាំទ្រដោយអនុវិស័យកាត់ដេរ អនុវិស័យមិនមែនកាត់ដេរដូចជា ផលិតកម្មចំណីអាហារនិងភេសជ្ជៈ គ្រឿងបង្គុំនិងដំឡើងរថយន្ត និងគ្រឿងបរិក្ខារអេឡិចត្រូនិក។ ដោយឡែក អនុវិស័យសំណង់នៅបន្តរងផលប៉ះពាល់ជាមួយនឹងកំណើនទាបក្នុងអត្រា ដែលការណ៍នេះបណ្តាលមកពីសកម្មភាពសំណង់ និងការសាងសង់នានានៅមានភាពថមថយនៅឡើយ។

វិស័យសេវាកម្ម ត្រូវបានរងផលប៉ះពាល់យ៉ាងខ្លាំងក្នុងអំឡុងវិបត្តិកូវីដ-១៩ ប៉ុន្តែបានត្រឡប់មកភាពល្អប្រសើរវិញក្នុងអត្រាកំណើន ៥,៦% នៅឆ្នាំ២០២៥ ។ វិស័យនេះ បានបង្ហាញពីសក្តានុពលនៃការងើបឡើងវិញយ៉ាងខ្លាំង ជាពិសេសអនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន និងរំពឹងថាបន្តមានកំណើនវិជ្ជមានរហូតដល់ឆ្នាំ២០២៧ ខណៈអនុវិស័យលក់ដុំ និងលក់រាយអាចរំពឹងពីកំណើនវិជ្ជមានជាមធ្យមក្នុងរង្វង់ ៥% រវាងឆ្នាំ២០២៤ ដល់ឆ្នាំ២០២៧។

ជារួម វិស័យចម្បងៗ ដែលបន្តមានកំណើនវិជ្ជមានក្នុងឆ្នាំបន្ទាប់រួមមាន វិស័យសេវាកម្ម និងវិស័យឧស្សាហកម្ម ដែលនឹងបង្ហាញភាពធន់ និងរឹងមាំនៃសេដ្ឋកិច្ចកម្ពុជា ព្រមទាំងការកើនឡើងនៃចំនួនការងារ និងកម្លាំងពលកម្មក្នុងឆ្នាំបន្តបន្ទាប់ ខណៈកម្លាំងពលកម្មក្នុងវិស័យកសិកម្មមាននិន្នាការថយចុះ ត្បិតតម្លៃបន្ថែមក្នុងវិស័យនេះបន្តមានកំណើនទាប។

## ខ. រចនាសម្ព័ន្ធទីផ្សារការងារ

ក្នុងផ្នែកនេះ សិស្ស-និស្សិត កម្មករនិយោជិត និយោជក អ្នកផ្តល់ការអប់រំនិងបណ្តុះបណ្តាល អ្នកគ្រប់គ្រងបុគ្គលិក អ្នកសិក្សាស្រាវជ្រាវ និងអ្នករៀបចំគោលនយោបាយ អាចស្វែងយល់បន្ថែមពីស្ថានភាពតម្រូវការទីផ្សារការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្ម ក្នុងរចនាសម្ព័ន្ធទីផ្សារការងារ។ តម្រូវការកម្លាំងពលកម្មបង្ហាញឱ្យឃើញតាមរយៈការបង្កើតការងារ, លក្ខខណ្ឌការងារ និងតម្រូវការជំនាញ ដែលពឹងផ្អែកលើការរីកចម្រើនវិស័យសេដ្ឋកិច្ច, ការវិនិយោគ, ការបណ្តុះបណ្តាលនិងជំនាញ, ការផ្លាស់ប្តូរបច្ចេកវិទ្យា និងការស្វែងរកការងារធ្វើ។ តុល្យភាពរវាងតម្រូវការការងារ និងការផ្គត់ផ្គង់កម្លាំងពលកម្ម គឺជាកត្តាចម្បងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងចំណូលជាតិដែលស្តែងឡើងតាមរយៈ កំណើនផ.ស.ស., តម្លៃបន្ថែមសរុប, ផលិតភាព ការងារ និងចំណែកចំណូលពលកម្ម។

ជាទូទៅ រចនាសម្ព័ន្ធទីផ្សារការងារ គឺពឹងផ្អែកលើស្ថានភាព ម៉ាក្រូសេដ្ឋកិច្ច និងមីក្រូសេដ្ឋកិច្ច ដែលបង្ហាញពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មនៅក្នុងទីផ្សារការងារ តាមរយៈភ្នាក់ងារសេដ្ឋកិច្ចសំខាន់ៗដូចខាងក្រោម៖

- ប្រជាជនដែលស្ថិតក្នុងវ័យធ្វើការ (១៥ ដល់ ៦៥ឆ្នាំ) ត្រូវបានកំណត់ថាជាចរន្តនៃការផ្គត់ផ្គង់កម្លាំងពលកម្ម រួមមាន ប្រជាជនដែលមានការងារធ្វើ ប្រជាជនគ្មានការងារធ្វើ និងប្រជាជននៅក្រៅកម្លាំងពលកម្ម។ ក្រុមប្រជាជន នៅក្រៅកម្លាំងពលកម្ម ត្រូវបានគេសម្គាល់ថាជាក្រុមកម្លាំងពលកម្មសក្តានុពល តែមិនបានចូលក្នុងទីផ្សារការងារ។
- សហគ្រាស គ្រឹះស្ថាន ត្រូវបានកំណត់ថាជាភ្នាក់ងារសេដ្ឋកិច្ចដែលមានតម្រូវការកម្លាំងពលកម្ម និងជំនាញ តាមរយៈការជ្រើសរើសកម្លាំងពលកម្មចូលបម្រើការក្នុងស្ថាប័នរបស់ខ្លួន និងការបង្កើតការងារថ្មី។
- សេដ្ឋកិច្ចក្នុងប្រទេស បង្ហាញពីចរន្តនៃតម្រូវការការងារ និងការផ្គត់ផ្គង់ការងារ តាមរយៈ ផ.ស.ស. តម្លៃបន្ថែមសរុប ផលិតភាពការងារ និងចំណែកចំណូលពលកម្មជាដើម។

**រូបភាពទី៣៖** រចនាសម្ព័ន្ធទីផ្សារការងារ



## ផ្នែកទី២៖ ការព្យាករនៃតម្រូវការការងារនៅកម្ពុជាក្នុងវិស័យសេវាកម្ម និងឧស្សាហកម្ម

ខណៈសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ត្រូវបានរំពឹងថានឹងកើនឡើងជាមួយនឹងអត្រាប្រចាំឆ្នាំជាមធ្យមរង្វង់ ៦% នៅចន្លោះឆ្នាំ២០២៤ ដល់ឆ្នាំ២០២៥ កំណើននេះត្រូវបានមើលឃើញថា នឹងបង្កើតឱកាសការងារជាច្រើននៅក្នុងវិស័យចម្បងរបស់កម្ពុជា ដូចជាវិស័យសេវាកម្ម និងឧស្សាហកម្ម ខណៈចំនួនការងារក្នុងវិស័យកសិកម្មនៅរក្សានិន្នាការថយចុះ។ ជារួម ការព្យាករកំណើនការងារ បានបង្ហាញពីភាពសុទិដ្ឋិនិយម ដោយចំនួនការងារសរុប កើនពី ៩,៨លាននាក់ ក្នុងឆ្នាំ២០២៣ ដល់ ១០,១លាននាក់ ក្នុងឆ្នាំ២០២៥ ជាពិសេស វិស័យសេវាកម្ម និងឧស្សាហកម្ម។

ការព្យាករកំណើនការងារក្នុងវិស័យសេវាកម្ម បានបង្ហាញពីសន្ទុះមួយគួរឱ្យកត់សម្គាល់ និងមានកំណើនខ្ពស់ជាងវិស័យកសិកម្ម និងឧស្សាហកម្ម។ ក្នុងនោះអត្រាកំណើនការងារអាចកើនជាមធ្យមក្នុងរង្វង់ ៩% ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ ។ កំណើននេះ ត្រូវបានគាំទ្រដោយអនុវិស័យដូចខាងក្រោម៖



ស្នាក់នៅ និងភោជនីយដ្ឋាន | អប់រំ | ហិរញ្ញវត្ថុ និងធានារ៉ាប់រង | សុខាភិបាល | បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានវិទ្យា (ICT) | ដឹកជញ្ជូន ឃ្លាំង និងភស្តុភារ

វិស័យឧស្សាហកម្ម ត្រូវបានគេរំពឹងថានឹងមានការកើនឡើងជាលំដាប់ ដោយអត្រាកំណើនការងារអាចកើនឡើងជាមធ្យមក្នុងរង្វង់ ២,៦% ពីឆ្នាំ២០២៣ ដល់ឆ្នាំ២០២៥ ។ តាមរយៈ ទិន្នន័យពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) បានបង្ហាញថា គម្រោងវិនិយោគថ្មីដែលបានអនុម័ត Qualified Investment Projects (QIPs) បង្ហាញពីសក្តានុពលក្នុងការជំរុញកំណើនសេដ្ឋកិច្ច និងការបង្កើតឱកាសការងារបន្ថែម ដោយកំណើននៃចំនួនគម្រោងវិនិយោគកើនឡើង ៥២,១% ក្នុងឆ្នាំ២០២៣ បើធៀបនឹងឆ្នាំ២០២២ និងអាចផ្តល់ឱកាសការងារបន្ថែមប្រមាណ ២៤០ពាន់កន្លែងក្នុងឆ្នាំ២០២៤ (ចំនួននៃឱកាសការងារបន្ថែមក្នុងឆ្នាំ២០២៤ គឺផ្អែកលើចំនួនគម្រោងវិនិយោគនៅក្នុងឆ្នាំ២០២៣)។ ក្នុងនោះ វិស័យកម្មន្តសាល បានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការផ្តល់ឱកាសការងារថ្មី ជាពិសេសនៅក្នុងអនុវិស័យសំខាន់ៗដូចជា អនុវិស័យកាត់ដេរ ការផលិតចំណីអាហារ និងភេសជ្ជៈ ផ្នែកគ្រឿងបង្គុំនិងដំឡើងរថយន្ត និងគ្រឿងបរិក្ខារអេឡិចត្រូនិកនិងអគ្គិសនី (បន្ទះសូឡា)។ ជាងនេះទៅទៀត កំណើនការងារអាចបន្តកើនឡើងខ្ពស់ជាងការព្យាករ ដែលជំរុញដោយអនុវិស័យដូចខាងក្រោម៖



សំណង់ | កាត់ដេរ | ផលិតអាហារ និងភេសជ្ជៈ | ផលិតកៅស៊ូ | ផលិតឈើ ក្រដាស និងបោះពុម្ព | កម្មន្តសាលផ្សេងៗ

**អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន៖** អនុវិស័យនេះបានបង្ហាញពីកំណើនក្រោយពេលវិបត្តិកូវីដ-១៩ ជាមួយនឹងអត្រា -២,៨% ក្នុងឆ្នាំ២០២៤ និង ៤,២% ក្នុងឆ្នាំ២០២៥ ។ អនុវិស័យនេះ រីកចម្រើនដោយការកើនឡើងនៃទេសចរណ៍ក្នុងស្រុក ក៏ដូចជាទេសចរណ៍បរទេស ដែលបង្កើនតម្រូវការសម្រាប់សណ្ឋាគារ ភោជនីយដ្ឋាន និងសេវាកម្មបដិសណ្ឋារកិច្ចផ្សេងៗទៀត។ ការអភិវឌ្ឍគម្រោងហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយរាជរដ្ឋាភិបាលក្នុងការទាក់ទាញវិនិយោគិនក្នុងស្រុក និងក្រៅស្រុក គឺជាកាតាលីករក្នុងការជំរុញកំណើនការងារក្នុងអនុវិស័យនេះ។

**រូបភាពទី៤៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យស្នាក់នៅ និងភោជនីយដ្ឋាន



**អនុវិស័យអប់រំ៖** អនុវិស័យនេះបង្ហាញពីអត្រាកំណើនការងារថេរសម្រាប់ឆ្នាំ២០២៤ និងឆ្នាំ២០២៥ ក្នុងរង្វង់ ២,៥%។ កំណើននេះ ឆ្លុះបញ្ចាំងពីការកើនឡើងនៃតម្រូវការ និងការវិនិយោគក្នុងវិស័យអប់រំ និងបណ្តុះបណ្តាលនៅកម្ពុជា ខណៈកម្ពុជាបាននិងកំពុងផ្តោតលើការអភិវឌ្ឍមូលធនមនុស្ស ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ការរីកដុះដាលស្ថាប័នអប់រំ និងគោលនយោបាយរាជរដ្ឋាភិបាល ក្នុងការលើកកម្ពស់គុណភាពអប់រំ សុទ្ធតែជាកត្តារួមចំណែកដល់ទស្សនវិស័យ វិជ្ជមាននៃកំណើនការងារ ក្នុងអនុវិស័យអប់រំនៅកម្ពុជា។

**រូបភាពទី៥៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យអប់រំ



**អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង៖** អនុវិស័យនេះមានក្រុមហ៊ុនចុះបញ្ជីជាង ៤ពាន់ក្រុមហ៊ុន និងបានផ្តល់ការងារសរុបចំនួនជាង ១៤០ពាន់កន្លែង។ អនុវិស័យនេះក៏ត្រូវបានព្យាករថានឹងមានកំណើនការងារគួរឱ្យកត់សម្គាល់ក្នុងអត្រាកំណើន ៣% ក្នុងឆ្នាំ២០២៤ និង ៦% សម្រាប់ឆ្នាំ២០២៥ ខាងមុខ។ កំណើនការងារនេះ បានបង្ហាញពីស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់កម្ពុជា ក្នុងការកើនឡើងនៃតម្រូវការ និងលទ្ធភាពទទួលបានសេវាធនាគារ ដូចជា ហិរញ្ញប្បទាន កំណើននៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការកើនឡើងនៃផ្នែកធានារ៉ាប់រងជាដើម។

**រូបភាពទី៦៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យហិរញ្ញវត្ថុ និងធានារ៉ាប់រង



**អនុវិស័យសុខាភិបាល៖** អនុវិស័យនេះ បង្ហាញពីកំណើនការងារ ក្នុងអត្រាកំណើនការងារជាមធ្យម ៤% សម្រាប់ឆ្នាំ ២០២៤ និងឆ្នាំ២០២៥ ។ នេះឆ្លុះបញ្ចាំងពីការកើនឡើងនៃតម្រូវការសេវាថែទាំសុខភាព និងសេវាសង្គមនៅកម្ពុជា នៅពេលដែលចំនួនប្រជាជនកើនឡើង ហើយរាជរដ្ឋាភិបាលបានវិនិយោគលើការកែលម្អហេដ្ឋារចនាសម្ព័ន្ធថែទាំសុខភាព និងកម្មវិធីនានាដែលធានាសុខុមាលភាពសង្គម។

**រូបភាពទី៧៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យសុខាភិបាល



**អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា (ICT)៖** អនុវិស័យនេះត្រូវបានរំពឹងថានឹងឃើញកំណើនការងារ ៥% ក្នុងឆ្នាំ២០២៤ និង ៨% ក្នុងឆ្នាំ២០២៥ ខាងមុខ។ ការកើនឡើងយ៉ាងឆាប់រហ័សនេះ ឆ្លុះបញ្ចាំងពីការកើនឡើងនូវឌីជីថលនីយកម្មនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា តម្រូវការកើនឡើងនៃសេវាកម្មព័ត៌មានវិទ្យា និងការពង្រីកហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍។ សេដ្ឋកិច្ចឌីជីថល និងការទាក់ទាញវិនិយោគបរទេសក្នុងអនុវិស័យនេះ ត្រូវបានគេរំពឹងថានឹងជំរុញកំណើនរបស់ខ្លួនបន្ថែមទៀត និងបង្កើតឱកាសការងារបន្ថែមទៀតនៅក្នុងពេលខាងមុខនេះ។

**រូបភាពទី៨៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យបច្ចេកវិទ្យា គមនាគមន៍ និងព័ត៌មានវិទ្យា



**អនុវិស័យដឹកជញ្ជូន ឃ្លាំង និងភស្តុភារ៖** តាមការព្យាករអនុវិស័យនេះ មានកំណើនការងារគួរឱ្យកត់សម្គាល់ ជាមួយនឹងអត្រាកំណើន ៤% ក្នុងឆ្នាំ២០២៤ និង ៧% ក្នុងឆ្នាំ២០២៥ ។ កំណើនការងារក្នុងវិស័យដឹកជញ្ជូន ឃ្លាំង និងភស្តុភារនេះ ត្រូវបានគាំទ្រដោយការកើនឡើងនៃសកម្មភាពពាណិជ្ជកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការកើនឡើងនៃតម្រូវការដឹកជញ្ជូន និងសេវាកម្មដឹកជញ្ជូន។ ការរីកចម្រើននៃពាណិជ្ជកម្មអេឡិចត្រូនិក និងការកែលម្អហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ត្រូវបានគេរំពឹងថានឹងបង្កើតឱកាសបន្ថែមទៀតសម្រាប់ការពង្រីកទីផ្សារការងារនៅក្នុងអនុវិស័យនេះ។

**រូបភាពទី៩៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យដឹកជញ្ជូន ឃ្លាំង និងភស្តុភារ



**អនុវិស័យសំណង់៖** ការងារក្នុងអនុវិស័យសំណង់ត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រាកំណើនថយជាមធ្យម ០,៥៩% ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ។ កំណើនអវិជ្ជមាននេះ ត្រូវបានទទួលរងផលប៉ះពាល់ដោយសារការថយចុះនូវគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងការវិនិយោគលើអចលនទ្រព្យ នៅក្នុងប្រទេសកម្ពុជា។ ក្នុងចំណោមការងារសរុបប្រមាណ ៨៩៤ ពាន់កន្លែង នៃចំនួនក្រុមហ៊ុនចុះបញ្ជីចំនួន ២០៩០ ក្រុមហ៊ុន ចំនួនការងារដែលថយចុះមានប្រមាណ ៥ ពាន់កន្លែងក្នុងមួយឆ្នាំ។

**រូបភាពទី១០៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យសំណង់



**អនុវិស័យកាត់ដេរ៖** អនុវិស័យនេះ បង្ហាញពីកំណើនយឺតយ៉ាវនៅឡើយ ដោយត្រូវបានព្យាករថានឹងកើន ជាមួយនឹងអត្រាកំណើន ៣% និង ៤% សម្រាប់ឆ្នាំ២០២៤ និងឆ្នាំ២០២៥ ។ កំណើនកម្រិតមធ្យមនេះ អាចបណ្ដាលមកពីការបង្កើនការប្រកួតប្រជែងពីប្រទេសផ្សេងទៀតនៅក្នុងតំបន់ ការកើនឡើងតម្លៃពលកម្ម និងតម្រូវការដើម្បីផ្លាស់ប្ដូរខ្សែច្រវ៉ាក់តម្លៃឆ្ពោះទៅរកវិស័យដែលមានតម្លៃបន្ថែមខ្ពស់ និងវិស័យសេវាកម្មជាដើម។ ការលើកកម្ពស់ផលិតភាពការងារ និងការធ្វើពិពិធកម្មឧស្សាហកម្មកាត់ដេរឆ្ពោះទៅរកផលិតផលដែលមានតម្លៃខ្ពស់ជាង អាចជួយកាត់បន្ថយបញ្ហាប្រឈមមួយចំនួន នៃអនុវិស័យនេះ។

**រូបភាពទី១១៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យកាត់ដេរ



**អនុវិស័យផលិតអាហារ និងភេសជ្ជៈ៖** អនុវិស័យនេះ ត្រូវបានព្យាករថានឹងមានកំណើនចំនួនការងារក្នុងអត្រាកំណើន ៩% ក្នុងឆ្នាំ២០២៤ និង ១២% ក្នុងឆ្នាំ២០២៥ ។ កំណើននេះទំនងជាត្រូវបានជំរុញដោយការពង្រីកទីផ្សារក្នុងស្រុករបស់កម្ពុជា ការកើនឡើងនៃវិស័យទេសចរណ៍ និងការបង្កើនឱកាសនាំចេញសម្រាប់អាហារកែច្នៃ និងភេសជ្ជៈ។ គំនិតផ្តួចផ្តើមកែច្នៃម្ហូបអាហារ រួមជាមួយនឹងការកើនឡើងនៃតម្រូវការអ្នកប្រើប្រាស់សម្រាប់ផលិតផលម្ហូបអាហារដែលមានសុវត្ថិភាព និងគុណភាពខ្ពស់ គឺជាកត្តាជំរុញកំណើនការងារក្នុងអនុវិស័យនេះបន្ថែមទៀត។

**រូបភាពទី១២៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យផលិតអាហារ និងភេសជ្ជៈ



**អនុវិស័យផលិតកៅស៊ូ៖** អនុវិស័យនេះ បានផ្តល់ការងារសរុបចំនួនជាង ១៩,៣ពាន់កន្លែង និងមានក្រុមហ៊ុនបានចុះបញ្ជីចំនួន ១៧៧ ។ អនុវិស័យនេះបានបង្ហាញពីកំណើនការងារគួរឱ្យកត់សម្គាល់ ក្នុងអត្រាកំណើនរង្វង់ ១៧% ឆ្នាំ២០២៤ និង ១០% ក្នុងឆ្នាំ២០២៥ ដែលត្រូវនឹងការកើនឡើងចំនួនការងារសរុបជាង ៥ពាន់កន្លែង សម្រាប់ទាំងពីរឆ្នាំ។ កំណើននេះបានមកពីការកើនឡើងនៃតម្រូវការសកលសម្រាប់ផលិតផលកៅស៊ូ និងកិច្ចខិតខំប្រឹងប្រែង ក្នុងការពង្រីកចំការកៅស៊ូ និងរោងចក្រកែច្នៃ។

**រូបភាពទី១៣៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យផលិតកៅស៊ូ



**អនុវិស័យផលិតឈើ ក្រដាស និងបោះពុម្ព៖** អនុវិស័យនេះ បង្ហាញពីកំណើនជាលំដាប់ ជាមួយនឹងកំណើនការងារដែលត្រូវបានព្យាករថានឹងកើនឡើងក្នុងអត្រាថេររង្វង់ ៤% ក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥ ។ ស្ថិរភាពនេះ អាចបណ្តាលមកពីតម្រូវការសម្ភារៈវេចខ្ចប់ ផលិតផលក្រដាស និងសេវាកម្មបោះពុម្ព ដែលជំរុញដោយការប្រើប្រាស់ក្នុងស្រុក និងទីផ្សារនាំចេញ។ អនុវិស័យនេះក៏មានបញ្ហាប្រឈមដូចជាតម្រូវការសម្រាប់ការអនុវត្តការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ការលើកទឹកចិត្តដល់ការប្រើប្រាស់សម្ភារៈកែច្នៃឡើងវិញនៅក្នុងឧស្សាហកម្មក្រដាស និងបោះពុម្ព អាចបង្កើតកំណើនការងារក្នុងអនុវិស័យនេះ។

**រូបភាពទី១៤៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យផលិតឈើ ក្រដាស និងបោះពុម្ព



**អនុវិស័យកម្មន្តសាលផ្សេងៗ៖** អនុវិស័យនេះ នឹងមានកំណើនអវិជ្ជមានរង្វង់ ៥,១% ក្នុងឆ្នាំ២០២៤ និង ៤,៥% ក្នុងឆ្នាំ២០២៥ ដែលការធ្លាក់ចុះនេះបង្ហាញពីភាពចាំបាច់នៃការបង្កើនការវិនិយោគទាំងក្នុងស្រុក និងក្រៅស្រុក ព្រមទាំងការអភិវឌ្ឍជំនាញ ដែលនឹងជំរុញឱ្យមានកំណើនការងារមកវិញ។ ការថយចុះនៃកំណើនការងារក្នុងអនុវិស័យនេះ អាចបណ្តាលមកពីកត្តាមួយចំនួនដូចជា ការប្រកួតប្រជែងពីបរទេស ការប្រែប្រួលនៃតម្រូវការទីផ្សារ ផលប៉ះពាល់នៃវិបត្តិកូវីដ-១៩ កង្វះកម្លាំងពលកម្មជំនាញ និងកង្វះខាតហេដ្ឋារចនាសម្ព័ន្ធ ដែលទាមទារឱ្យមានកិច្ចសហការដើម្បីដោះស្រាយ និងជំរុញកំណើនការងារឡើងវិញ។

**រូបភាពទី១៥៖** ព័ត៌មានទីផ្សារការងារ សម្រាប់អនុវិស័យកម្មន្តសាលផ្សេងៗ



## ផ្នែកទី៣៖ តម្រូវការមុខរបរក្នុងទីផ្សារការងារតាមកម្រិតនៃជំនាញ និងមុខតំណែង

ការវាយតម្លៃមុខរបរដែលមានឱកាសការងារល្អ ត្រូវបានពឹងផ្អែកលើលក្ខណវិនិច្ឆ័យសំខាន់ៗចំនួន ៥ ដូចជា ស្ថានភាពជ្រើសរើសបុគ្គលិក ដង់ស៊ីតេដំណឹងជ្រើសរើសបុគ្គលិក ប្រាក់ខែ កំណើនការងារ និងកំណើនរបស់វិស័យ។ រាល់ការជ្រើសរើសមុខរបរដែលមានតម្រូវការទីផ្សារខ្ពស់ និងឱកាសការងារល្អត្រូវបានពឹងផ្អែកលើលក្ខណវិនិច្ឆ័យទាំង៥ ដូចក្នុងតារាងខាងក្រោម។

**តារាងទី១៖** លក្ខណវិនិច្ឆ័យទាំង ៥ ក្នុងការធ្វើចំណាត់ថ្នាក់មុខរបរដែលមានតម្រូវការខ្ពស់

| លក្ខណវិនិច្ឆ័យ | បរិយាយ |
|---|---|
| ស្ថានភាពជ្រើសរើស ឬឱកាសការងារសម្រាប់មុខរបរដែលមានឱកាសខ្ពស់ | ការវាយតម្លៃស្ថានភាពជ្រើសរើសត្រូវបានគណនាឡើងពី ២ប្រភពទិន្នន័យរួមមាន ទិន្នន័យជ្រើសរើសបុគ្គលិក របស់មជ្ឈមណ្ឌលការងារខេត្ត និងក្រុងទាំង១៣ របស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ និងពីការអង្កេតដែលក្រសួងបានធ្វើលើសហគ្រាស គ្រឹះស្ថានចំនួន ៥៧៧។ បន្ថែមពីនេះ លទ្ធផលសន្ទស្សន៍នេះ ក៏ត្រូវបានឆ្លងកាត់ការផ្តល់មតិយោបល់ និងវាយតម្លៃពីសំណាក់អ្នកជំនាញខាងធនធានមនុស្សផងដែរ មុននឹងសម្រេចចេញជាសន្ទស្សន៍ឱកាសការងារសម្រាប់មុខរបរនីមួយៗ។ ជាលទ្ធផល សន្ទស្សន៍នេះត្រូវបានយកមកធ្វើជាព័ត៌មានមូលដ្ឋានក្នុងការជ្រើសរើសមុខរបរដែលមានឱកាសការងារល្អ។ |
| ដង់ស៊ីតេដំណឹងជ្រើសរើសបុគ្គលិក | ការគណនាសន្ទស្សន៍ឱកាសការងារនេះ ត្រូវបានដាក់ទម្ងន់ជាមួយនឹងដង់ស៊ីតេដំណឹងជ្រើសរើសបុគ្គលិកទៅតាមមុខរបរនីមួយៗ។ សម្រាប់ការជ្រើសរើសមុខតំណែង ក៏ត្រូវបានពិចារណាលើចំនួនជ្រើសរើសបុគ្គលិក និងសន្ទស្សន៍ឱកាសការងារទៅតាមមុខរបរនីមួយៗ។ |
| ប្រាក់ខែ | ទិន្នន័យប្រាក់ខែត្រូវបានគណនាឡើង ដោយការដាក់ទម្ងន់ទៅលើចំនួនអ្នកមានការងារក្នុងមុខរបរដូចគ្នា រួចគណនាជាមធ្យមសម្រាប់មុខតំណែងនីមួយៗ។ បន្ទាប់មក ត្រូវបានកែសម្រួលជាមួយទិន្នន័យរបស់ទីភ្នាក់ងារជាតិមុខរបរ និងការងារ។ |
| កំណើនការងារ | ការជ្រើសរើសមុខរបរ ដែលមានសក្តានុពលខ្ពស់ត្រូវបានពឹងផ្អែកលើកំណើនការងារតាមមុខរបរដែលបានព្យាករចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា។ |
| កំណើនរបស់វិស័យ | ការជ្រើសរើសមុខរបរ ដែលមានសក្តានុពលខ្ពស់ត្រូវបានពឹងផ្អែកលើកំណើនរបស់វិស័យដែលបានព្យាករចេញពីទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ |

មុខរបរដែលមានតម្រូវការទីផ្សារការងារខ្ពស់ ត្រូវបានដកស្រង់ចេញពីមុខរបរសរុបចំនួន ២៤០ ដែលមាននៅក្នុងអនុវិស័យទាំង១២ ខាងលើ។ ការបែងចែកមុខរបរទៅតាមកម្រិតជំនាញ និងមុខតំណែងនេះ អាចជួយឱ្យការជ្រើសរើសមុខរបរដែលមានសក្តានុពល និងឱកាសការងារល្អ អាចកំណត់ទិសដៅ និងផែនការអាជីពរបស់ខ្លួនបានកាន់តែច្បាស់លាស់ ដោយផ្តោតលើការអភិវឌ្ឍជំនាញ និងបទពិសោធដែលសមស្របទៅតាមសក្តានុពល និងចំណាប់អារម្មណ៍របស់ខ្លួន។ ការស្វែងយល់ពីឱកាសការងារ និងមុខរបរដែលមានតម្រូវការខ្ពស់ត្រូវបានបែងចែកជាកម្រិតជំនាញ មុខតំណែង កម្រិតនៃការសិក្សា និងបទពិសោធការងារ[1] ដូចក្នុងតារាងខាងក្រោម។

[1] ចំណាត់ថ្នាក់ស្តង់ដាអន្តរជាតិមុខរបរ (ISCO-08) របស់អង្គការអន្តរជាតិខាងការងារ (ILO)

**តារាងទី២៖** មុខរបរដែលមានតម្រូវការខ្ពស់ តាមកម្រិតជំនាញ

| | | | | | |
|---|---|---|---|---|---|
| **អ្នកគ្រប់គ្រង៖** ជាកម្រិតអ្នកដឹកនាំស្ថាប័ន ដែលទាមទារកម្រិតអប់រំចាប់ពី បរិញ្ញាបត្រឡើងទៅ និងមានបទពិសោធយ៉ាងតិច ១០ឆ្នាំ | នាយកគ្រប់គ្រងពាណិជ្ជកម្ម និងរដ្ឋបាល  | នាយកគ្រប់គ្រងសេវាសុខភាព  | នាយកគ្រប់គ្រងការសាងសង់  | នាយកគ្រប់គ្រងសណ្ឋាគារ  | នាយកគ្រប់គ្រងការស្រាវជ្រាវ  |
| **អ្នកជំនាញជាន់ខ្ពស់ និងអ្នកឯកទេស៖** ជាកម្រិតអ្នកជំនាញជាន់ខ្ពស់ និងអ្នកឯកទេស ដែលទាមទារកម្រិតអប់រំចាប់ពី បរិញ្ញាបត្រឡើងទៅ និងមានបទពិសោធយ៉ាងតិច ៥ឆ្នាំ | វេជ្ជបណ្ឌិតជំនាញឯកទេស  | គណនេយ្យករកម្រិតខ្ពស់ ឬសវនករ  | វិស្វករឧស្សាហកម្ម និងផលិតកម្ម  | ឱសថការី  | វិស្វករសំណង់ស៊ីវិល  |
| | អ្នកវិភាគប្រព័ន្ធព័ត៌មានវិទ្យា  | អ្នកអភិវឌ្ឍវេបសាយ  | វិស្វករអគ្គិសនី  | អ្នកសរសេរកម្មវិធីកុំព្យូទ័រ  | គ្រូបង្រៀនអប់រំវិជ្ជាជីវៈ  |
| | អ្នកវិភាគគ្រប់គ្រង និងរដ្ឋបាល  | មេធាវី  | វិស្វករអេឡិចត្រូនិក  | វិស្វករទូរគមនាគមន៍  | អ្នកជំនាញផ្នែកធនធានមនុស្ស  |
| **អ្នកបច្ចេកទេស និងអ្នកជំនាញរង៖** ជាកម្រិតអ្នកបច្ចេកទេស និងអ្នកជំនាញរង ដែលទាមទារកម្រិតអប់រំចាប់ពី បរិញ្ញាបត្ររងឡើងទៅ និងមានបទពិសោធយ៉ាងតិច ១ឆ្នាំ | មេចុងភៅ  | អ្នកបច្ចេកទេសខាងផ្សព្វផ្សាយ  | បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម  | មន្ត្រីឥណទាន  | អ្នកបច្ចេកទេសគ្រឿងម៉ាស៊ីន  |
| | អ្នកត្រួតពិនិត្យចរាចរណ៍ផ្លូវអាកាស  | អ្នកបច្ចេកទេសអគ្គិសនី  | គិលានុបដ្ឋាយិកា  | អ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រ  | ជំនួយការគណនេយ្យករ  |
| **បុគ្គលិកគាំទ្រ និងលេខាធិការ៖** ជាកម្រិតផ្នែកបុគ្គលិកគាំទ្រ និងស្មៀន ដែលទាមទារកម្រិតអប់រំបរិញ្ញាបត្ររងឡើងទៅ | បុគ្គលិកផ្នែកធនធានមនុស្ស  | បុគ្គលិកផ្នែកផលិតកម្ម  | បុគ្គលិកផ្នែកគណនេយ្យ និងបញ្ជី  | អ្នកទទួលភ្ញៀវនៅសណ្ឋាគារ  | អ្នកទទួលភ្ញៀវ  |

| | | | | | |
|---|---|---|---|---|---|
| **បុគ្គលិកផ្នែកលក់ និងសេវាកម្ម៖** ជាកម្រិតបុគ្គលិកផ្នែកលក់ និង បម្រើសេវាកម្ម ដែលទាមទារ កម្រិតអប់រំចាប់ពីថ្នាក់ទី៩ ឬ សញ្ញាបត្របច្ចេកទេស និង វិជ្ជាជីវៈ១(C1)ឡើងទៅ | អ្នកគ្រប់គ្រងហាង  | អ្នកក្រឡុកស្រា*  | អ្នកថែទាំក្មេង  | សន្តិសុខ  | ជាងកាត់សក់*  |
| | ចុងភៅ*  | អ្នកធ្វើការសេវាកម្មចំណីអាហារ*  | ជំនួយការគ្រូបង្រៀន  | អ្នកពន្លត់អគ្គិភ័យ  | បាហុនិកា (អូតេស)  |
| **កម្មករជំនាញសិប្បកម្ម និងការកែច្នៃដោយដៃ៖** ជាកម្រិតកម្មករ ឬសិប្បករ ដែលទាមទារកម្រិតអប់រំចាប់ពី ថ្នាក់ទី៩ ឬសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1)ឡើងទៅ | ជាងកែច្នៃឈើ*  | ជាងទឹក*  | ជាងផ្សារដែក*  | ជាងជួសជុលម៉ាស៊ីន*  | ជាងអគ្គិសនី*  |
| | ជាងអេឡិចត្រូនិក*  | ជាងសំណង់*  | អ្នកដុតនំ*  | ជាងកាត់ដេរសម្លៀកបំពាក់*  | ជាងដំបូល*  |
| **កម្មករខាងបញ្ជាម៉ាស៊ីន និងដំឡើងគ្រឿងចក្រ៖** ជាកម្រិតកម្មករ ដែលទាមទារជំនាញវិជ្ជាជីវៈ | អ្នកបញ្ជាឡានស្ទូច  | អ្នកបញ្ជាម៉ាស៊ីនផលិតផលស៊ីម៉ង់ត៍  | អ្នកដំឡើងម៉ាស៊ីនយានយន្ត*  | អ្នកបញ្ជាគ្រឿងចក្រក្នុងរោងចក្រ  | អ្នកបើកបររថយន្តដឹកទំនិញ  |

*កំណត់សម្គាល់៖ ជំនាញដែលមានក្នុងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (1.5M) ។

## ផ្នែកទី៤៖ មុខរបរមានតម្រូវការខ្ពស់ទាំង២០ សម្រាប់យុវជន ដែលស្វែងរកការងារដំបូង

តារាងខាងក្រោមបង្ហាញពីមុខតំណែងមានតម្រូវការខ្ពស់ទាំង២០ ដែលត្រូវបានស្វែងរកច្រើនបំផុតក្នុងចំណោមអ្នកស្វែងរកការងារជាយុវជន ពេលស្វែងរកការងារជាលើកដំបូង។ តារាងនេះផ្តល់ព័ត៌មានដ៏មានតម្លៃចំពោះការជ្រើសរើសអាជីព និងតម្រូវការនៃកម្លាំងពលកម្មដែលកំពុងរីកចម្រើន ដោយគូសបញ្ជាក់ពីវិស័យ និងមុខតំណែងដែលមានតម្រូវការខ្ពស់សម្រាប់យុវជន។ ទិន្នន័យនេះផ្តល់នូវរូបភាពនៃនិន្នាការទីផ្សារការងារបច្ចុប្បន្ន ហើយក៏ជាព័ត៌មានសម្រាប់និយោជក អ្នកអប់រំ និងយុវជន ក្នុងការយល់ដឹងអំពីសក្តានុពលនៃទិដ្ឋភាពការងារ។ សម្រាប់ព័ត៌មានទីផ្សារការងារ និងមុខរបរបន្ថែមសូមចូលទៅកាន់គេហទំព័រ www.nea.gov.kh។

**តារាងទី៣៖** មុខរបរមានតម្រូវការខ្ពស់ទាំង២០ សម្រាប់យុវជន

| ឈ្មោះមុខរបរ | ព័ត៌មានអំពីការងារ និងលក្ខខណ្ឌតម្រូវ | ប្រាក់ខែ (ដុល្លារ) | អនុវិស័យ |
|---|---|---|---|
|  គណនេយ្យករកម្រិតខ្ពស់ ឬសវនករ | -រៀបចំ គ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធគណនេយ្យហិរញ្ញវត្ថុ<br>-កម្រិតបរិញ្ញាបត្រ ឡើងទៅ | 600 - 800 | ហិរញ្ញវត្ថុ និងធានារ៉ាប់រង |
|  គ្រូបង្រៀននៅសាកលវិទ្យាល័យ និងឧត្តមសិក្សា | -ស្រាវជ្រាវ រៀបចំឯកសារសិក្សា និងផ្តល់ការបង្រៀននៅសាកលវិទ្យាល័យ<br>-កម្រិតបរិញ្ញាបត្រជាន់ខ្ពស់ឡើងទៅ | 400 - 600 | អប់រំ |
|  វិស្វករឧស្សាហកម្ម និងផលិតកម្ម | -ស្រាវជ្រាវ រៀបចំ សម្របសម្រួល និងត្រួតពិនិត្យ ដំណើរការផលិតកម្ម<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 300 - 600 | គ្រប់វិស័យកម្មន្តសាល |
|  គ្រូបង្រៀននៅថ្នាក់មធ្យមសិក្សា | -បង្រៀនសិស្សតាមកម្មវិធីដែលមានក្នុងក្រសួងអប់រំ យុវជន និងកីឡា<br>-កម្រិតវិជ្ជាជីវៈគ្រូបង្រៀន | 350 - 450 | អប់រំ |
|  អ្នកតំណាងលក់ផ្នែកពាណិជ្ជកម្ម | -ផ្តល់យោបល់ ពីសេវាកម្មលក់ ផលិតផល<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 350 - 450 | ហិរញ្ញវត្ថុ និងបច្ចេកវិទ្យា និងព័ត៌មានវិទ្យា (ICT) |
|  វិស្វករសំណង់ស៊ីវិល | -គ្រប់គ្រងការសាងសង់ និងរចនាសម្ព័ន្ធសំណង់ដោយបច្ចេកទេស<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 300 - 600 | សំណង់ |
|  ចុងភៅ | -រៀបចំគ្រឿងចម្អិនម្ហូបតាមការគ្រប់គ្រងរបស់ចុងភៅ<br>-សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១(C1)ឡើងទៅ | 300 - 600 | ស្នាក់នៅ និងភោជនីយដ្ឋាន |
| បុគ្គលិក ឬជំនួយការផ្នែកធនធានមនុស្ស | -ធ្វើបច្ចុប្បន្នភាពកំណត់ត្រាបុគ្គលិក ដូចជាប្រាក់ខែ និងការវាយតម្លៃ<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 300 - 600 | គ្រប់វិស័យ |
|  វិជ្ជាជីវៈខាងទំនាក់ទំនងសាធារណៈ | -បង្កើត អនុវត្ត និងរៀបចំផែនការទំនាក់ទំនងឱ្យមានប្រសិទ្ធភាព<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 300 - 600 | ហិរញ្ញវត្ថុ និងធានារ៉ាប់រង |
|  អ្នកបច្ចេកទេសគាំទ្រដល់អ្នកប្រើប្រាស់នូវបច្ចេកវិទ្យាគមនាគមន៍ព័ត៌មាន | -ផ្តល់ជំនួយ និងដោះស្រាយបញ្ហាដល់អ្នកប្រើប្រាស់បច្ចេកវិទ្យា<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 300 - 600 | គ្រប់វិស័យ |
|  វិជ្ជាជីវៈខាងគិលានុបដ្ឋាយិកា | -ផ្តល់សេវាព្យាបាល ថែទាំ ពិនិត្យ គ្រប់គ្រងអ្នកជំងឺ<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 300 - 600 | សុខាភិបាល |
|  វិស្វករអគ្គិសនី | -ស្រាវជ្រាវ ថែទាំ សិក្សា និងជួសជុលលើប្រព័ន្ធបច្ចេកវិទ្យាអគ្គិសនី<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 300 - 600 | សំណង់ និងផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី |
|  អ្នកបច្ចេកទេសខាងវិស្វកម្មអេឡិចត្រូនិក | -ស្រាវជ្រាវ ថែទាំ ប្រតិបត្តិការ និងជួសជុលគ្រឿងអេឡិចត្រូនិក<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 300 - 500 | ផលិតគ្រឿងអេឡិចត្រូនិក និងឧបករណ៍អគ្គិសនី |
|  បុគ្គលិកទូទៅផ្នែកកត់ត្រាគណនេយ្យ និងបញ្ជី | -គណនា ចាត់ថ្នាក់ កត់ត្រា និងផ្ទៀងផ្ទាត់គណនេយ្យហិរញ្ញវត្ថុ<br>-កម្រិតបរិញ្ញាបត្ររងឡើងទៅ | 300 - 450 | ហិរញ្ញវត្ថុ និងធានារ៉ាប់រង |

| | | | | |
|---|---|---|---|---|
|  | ភ្នាក់ងារខាងមូលប័ត្រ និងហិរញ្ញវត្ថុ | -ទិញលក់មូលបត្រភាគហ៊ុន បំណុល និងសេវាហិរញ្ញវត្ថុផ្សេងទៀត<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 300 -500 | ហិរញ្ញវត្ថុ និងធានារ៉ាប់រង |
|  | គ្រូបង្រៀនអប់រំវិជ្ជាជីវៈ | -បង្រៀន ណែនាំមុខវិជ្ជាវិជ្ជាជីវៈ ក្នុងគ្រឹះស្ថានអប់រំសម្រាប់មនុស្សពេញវ័យ<br>-កម្រិតវិជ្ជាជីវៈគ្រូបង្រៀន | 300 - 500 | អប់រំ |
|  | បុគ្គលិកផ្គត់ផ្គង់ ឬលទ្ធកម្ម | -សម្របសម្រួលការបញ្ជាទិញសម្ភារ គ្រប់គ្រងការដឹកជញ្ជូន និងភស្តុភារ<br>-កម្រិតបរិញ្ញាបត្រឡើងទៅ | 250 – 500 | គ្រប់វិស័យ |
|  | អ្នកបច្ចេកទេសគ្រឿងម៉ាស៊ីន | -ជួសជុល និងត្រួតពិនិត្យគ្រឿងម៉ាស៊ីន<br>-សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1)ឡើងទៅ | 250 - 500 | គ្រប់វិស័យ |
|  | អ្នកទទួលភ្ញៀវក្នុងសណ្ឋាគារ | -ស្វាគមន៍ បម្រើសេវាកម្មសម្រាប់ភ្ញៀវនៅក្នុងសណ្ឋាគារ និងគ្រឹះស្ថានផ្សេងៗ<br>-សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1)ឡើងទៅ | 200 - 300 | ស្នាក់នៅ និងភោជនីយដ្ឋាន |
|  | អ្នកក្រឡុកស្រា | -រៀបចំ និងបម្រើភេសជ្ជៈដោយផ្ទាល់ទៅកាន់អតិថិជន<br>-សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1)ឡើងទៅ | 200 – 250 | ស្នាក់នៅ និងភោជនីយដ្ឋាន |

## ផ្នែកទី៥៖ ការចាប់យកឱកាសបណ្តុះបណ្តាល និងប្រឹក្សាយោបល់ការងារ

### ក. ឱកាសទទួលបានការបណ្តុះបណ្តាលដោយមិនគិតថ្លៃ និងទទួលបានប្រាក់ខែសមរម្យ

ដើម្បីបំពេញតម្រូវការទីផ្សារការងារបច្ចុប្បន្ន និងអនាគត និងផ្តល់ឱកាសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ព្រមទាំងកម្មករនិយោជិត និងប្រជាពលរដ្ឋទូទៅ ក្លាយជាកម្លាំងពលកម្មជំនាញប្រកបដោយសមត្ថភាព និងផលិតភាពខ្ពស់ ដែលជាចំណុចស្នូលសម្រាប់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី** បានដាក់ឱ្យអនុវត្តជាផ្លូវការ **«កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ»** ដោយមិនបង់ថ្លៃ និងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែ តាមអភិក្រម **"រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ"** លើវិស័យចំនួន ១០ និងជំនាញអាទិភាពចំនួន ៤៥មុខជំនាញ ដើម្បីឱ្យប្រជាពលរដ្ឋម្នាក់មានជំនាញមួយយ៉ាងតិចប្រចាំជីវិត និងអាចប្រកបមុខរបរការងារ សម្រាប់ចិញ្ចឹមជីវិត ព្រមទាំងអាចរកចំណូលប្រចាំថ្ងៃបានបន្ថែមទៀត។ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៤ នេះ មានអ្នកស្នើចុះឈ្មោះចូលរៀនចំនួន ៤៥ ៤០០នាក់, សិស្សកំពុងសិក្សាចំនួន ១៨ ១៦១នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ៧ ៤២៣នាក់) និងសិស្សបានបញ្ចប់ការសិក្សាមានចំនួន ៣ ៩១១នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ១ ៩១៣នាក់)។ សិស្សដែលបានបញ្ចប់ការសិក្សាក្នុងកម្មវិធីនេះបានទទួលការងារធ្វើតាមជំនាញដែលខ្លួនបានសិក្សា និងទទួលបានប្រាក់បៀវត្សសមរម្យ។ ខាងក្រោមនេះ គឺជាព័ត៌មានអំពីភាពជោគជ័យក្រោយបញ្ចប់ការសិក្សាក្នុងវគ្គនេះផងដែរ។ វិស័យដែលកំពុងបណ្តុះបណ្តាលទាំង ១០ និងជំនាញទាំង ៤៥ មុខវិជ្ជា៖


វិស័យ អាជីវកម្ម
វិស័យធុរកិច្ច និងព័ត៌មានវិទ្យា
សេវាកម្មធនធានមនុស្ស, សេវាកម្មកុំព្យូទ័រ, សេវាកម្មរដ្ឋបាល, សេវាកម្មអតិថិជន, រចនាក្រាហ្វិកដោយកុំព្យូទ័រ, ដំឡើងនិងថែទាំបណ្តាញកុំព្យូទ័រ, និងការដំឡើង និងអនុវត្តបច្ចេកវិទ្យាឌីជីថល
វិស័យសំណង់
ការងារកំបោរ,ដំឡើងបណ្តាញបំពង់ទឹក,ដំឡើងបណ្តាញអគ្គិសនីក្នុងអគារ, ដំឡើងពុម្ព, ការដំឡើងសរសៃដែក, ដំឡើងគ្រឿងឈើសម្រេច, ការងារការ៉ូ, និងដំឡើងដំបូល
វិស័យអគ្គិសនី និងថាមពល
ការថែទាំនិងជួសជុលម៉ូទ័រអគ្គិសនី, និងការដំឡើងប្រព័ន្ធបញ្ជាម៉ូទ័រអគ្គិសនី
វិស័យកសិកម្មនិងកសិ-ឧស្សាហកម្ម
ដាំថែទាំនិងប្រមូលផលស្វាយកែវរមៀត, ដាំថែទាំនិងប្រមូលផលស្វាយចន្ទី, ដាំថែទាំនិងប្រមូលផលមៀន, ចិញ្ចឹមនិងថែទាំត្រីប្រា, និងកែច្នៃបន្លែ និងផ្លែឈើ
វិស័យអេឡិចត្រូនិក
ថែទាំ និងជួសជុលបរិក្ខារបំពងសំឡេង, ការដំឡើងនិងថែទាំកាមេរ៉ាសុវត្ថិភាព, និងការថែទាំ និងជួសជុលទូរស័ព្ទដៃ
វិស័យបរិក្ខារត្រជាក់ និងកំដៅ
សេវាកម្មបរិក្ខារត្រជាក់ក្នុងគេហដ្ឋាន
វិស័យសេវាកម្ម
សេវាកម្មកាត់សក់បុរស, វាល់ក្អែក និងកាត់កញ្ចក់វែនតា, និងសេវាកម្មសម្អាងកាយ
វិស័យកម្មន្តសាល
ការបន្សាលោហៈ, ការផ្សារលោហៈដោយធ្នូអគ្គិសនី(ធូប), ការផ្សារអគ្គិសនី,ផ្សារឧស្ម័ន,ជួសជុលនិងថែទាំដណ្តើរយន្ត
វិស័យទេសចរណ៍
ធុរកិច្ចភេសជ្ជៈ,ការងារគេហកិច្ច,ផលិតនំ, និង ធ្វើម្ហូបខ្មែរ, ការងារការិយាល័យជួរមុខ, និងសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ
វិស័យមេកានិក/មេកានិករថយន្ត
ថែទាំ និងជួសជុលម៉ាស៊ីនត្រជាក់រថយន្ត, ថែទាំ និងជួសជុលរថយន្ត, ថែទាំ និងជួសជុលអគ្គិសនីរថយន្ត, ថែទាំ និងជួសជុលម៉ាស៊ីនធុនតូច, ថែទាំនិងជួសជុលទោចក្រយានយន្ត


ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
កម្មវិធី
បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
បានមានប្រសាសន៍ថា៖ គោលដៅនៃការបណ្តុះបណ្តាលនេះគឺ "រៀនឱ្យចប់ ឱ្យចេះ ឱ្យមានការងារ"
អត្ថប្រយោជន៍
- សិក្សាដោយមិនបង់ថ្លៃ
- ប្រាក់ឧបត្ថម្ភប្រចាំខែ ដោយសិក្សាពេញម៉ោង
- ផ្តល់ប្រឹក្សាយោបល់ពីការជ្រើសរើសជំនាញ និងព័ត៌មានទីផ្សារការងារ
- កន្លែងចុះកម្មសិក្សានៅតាមសហគ្រាស គ្រឹះស្ថាន
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ និងឱកាសបន្តការសិក្សា
- ជំនាញមួយពិតប្រាកដដែលទីផ្សារការងារកំពុងត្រូវការ
- ឱកាសការងារធ្វើសមរម្យ និងចំណូលទៀងទាត់
ក្រុមគោលដៅ
- យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យទូទាំងប្រទេស (ចូលរៀនដោយមិនបង់ថ្លៃ និងទទួលបានប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលបណ្តុះបណ្តាល)
- បងប្អូនកម្មករនិយោជិត និងបុគ្គលនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (អាចចូលរៀនដោយមិនបង់ថ្លៃ)
ការចុះឈ្មោះចូលរៀន
- តាមប្រព័ន្ធឌីជីថល៖
✓ www.tvet.gov.kh
✓ Mobile App: TVET 1.5M
- តាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទូទាំងប្រទេស
ស្កេនទីនេះដើម្បីចុះឈ្មោះ
សូមទំនាក់ទំនង
១២៨៦ / ១២៩៧
វេនសិក្សា
វេនសិក្សា | ព្រឹក | រសៀល | យប់ | ចំនួនខែ
ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ | ៨:០០-១២:០០ | ១៣:៣០-១៦:៣០ | | ៤
ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ | ៨:០០-១២:០០ | | | ៦
ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ | | ១៣:០០-១៧:០០ | | ៦
ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ | | | ១៧:៣០-២០:៣០ | ៨
ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ | | | ១៨:០០-២០:០០ | ១១
ថ្ងៃសៅរ៍ និងអាទិត្យ | ៨:០០-១២:០០ | ១៣:០០-១៧:០០ | | ៨
ថ្ងៃអាទិត្យ | ៨:០០-១២:០០ | ១៣:០០-១៧:០០ | | ១២
កំណត់សម្គាល់៖
- វេនសិក្សាពេញម៉ោង ថ្ងៃចន្ទ ដល់ ថ្ងៃសុក្រ សិក្សារយៈពេល ៤ខែ។
- វេនសិក្សាផ្សេងៗទៀតត្រូវអនុវត្តដោយមានលក្ខខណ្ឌតម្រូវ។
- វេនសិក្សាថ្ងៃអាទិត្យចំនួន ១២ខែត្រូវបញ្ចូលជាមួយថ្នាក់រៀនតាមប្រព័ន្ធអនឡាញ។
វិស័យសម្រាប់បណ្តុះបណ្តាល
១. សំណង់
២. អគ្គិសនី និងថាមពល
៣. អេឡិចត្រូនិក
៤. បរិក្ខារត្រជាក់ និងកម្តៅ
៥. កម្មន្តសាល
៦. មេកានិកទូទៅ/មេកានិករថយន្ត
៧. ទេសចរណ៍
៨. សេវាកម្ម
៩. កសិកម្ម និងកសិ-ឧស្សាហកម្ម
១០. ធុរកិច្ច និងព័ត៌មានវិទ្យា
TVET FOR ALL
យុវជន បងប្អូនកម្មករនិយោជិតដែលត្រូវការផ្លាស់ប្តូរជំនាញ បង្កើនជំនាញ ឬបង្កើនផលិតភាពពេញមួយជីវិត រួមទាំងនិយោជក ម្ចាស់សហគ្រាសដែលមានបំណងបង្កើនប្រសិទ្ធភាព ផលិតភាពការងារ និងភាពប្រកួតប្រជែងខ្ពស់ ឬចំណេះដឹងផ្នែកសហគ្រិនភាពនិងផ្នែកផ្សេងៗប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន!

លោក សេង ម៉ៅ អាយុ ៣៨ឆ្នាំ មានទីលំនៅ នៅរាជធានីភ្នំពេញ បានបញ្ចប់ការសិក្សាជំនាញថែទាំ និងជួសជុលរថយន្ត ពីវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម បច្ចុប្បន្ន ធ្វើការនៅក្រុមហ៊ុនវីរៈប៊ុនថាំ។



“បន្ទាប់ពីបានបញ្ចប់ការសិក្សា ថែទាំ និងជួសជុលរថយន្ត ពីវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម ខ្ញុំទទួលបានឱកាសការងារដ៏សមរម្យមួយនៅក្រុមហ៊ុនវីរៈប៊ុនថាំ ព្រមទាំងមានប្រាក់បៀវត្សអាចជួយជីវភាពគ្រួសារឱ្យមានភាពប្រសើរជាងមុន។ នៅថ្ងៃអនាគត ខ្ញុំមានគោលបំណង បើកយានដ្ឋាន ថែទាំ និងជួសជុលរថយន្តផ្ទាល់ខ្លួន។”



យុវជន វុទ្ធី ភារុណ អាយុ ១៧ឆ្នាំ មានទីលំនៅ នៅរាជធានីភ្នំពេញ បានបញ្ចប់ការសិក្សាជំនាញ សេវាកម្មបរិក្ខារត្រជាក់ក្នុងគេហដ្ឋានពីវិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម។ បច្ចុប្បន្នគាត់កំពុងបម្រើការនៅក្រុមហ៊ុន CDS នៅរាជធានីភ្នំពេញ។

“ក្រោយពីបញ្ចប់ការសិក្សាពី «កម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស សម្រាប់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ» ដោយទទួលបានប្រាក់បៀវត្សប្រចាំខែ ចំនួន ២៨ម៉ឺនរៀល។ ខ្ញុំទទួលបានឱកាសការងារដ៏សមរម្យមួយដែលធ្វើឱ្យជីវភាពខ្ញុំក៏ដូចជាគ្រួសារមានភាពប្រសើរជាងមុន។ គោលដៅនាថ្ងៃអនាគត ខ្ញុំចង់ក្លាយជា អ្នកជំនាញឯកទេសខាងបរិក្ខារត្រជាក់ ព្រមទាំងមានអាជីវកម្មផ្ទាល់ខ្លួន ដើម្បីទទួលបានប្រាក់ចំណូលកាន់តែប្រសើរជាងមុន។”

### គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សាធារណៈនៅតាមរាជធានី ខេត្ត

១. វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា (ភ្នំពេញ)
លេខទូរសព្ទ៖ ០៦០ ២៧៨ ៨៨៩/០៧០ ២៧៨ ៨៨៩
២. វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស (ភ្នំពេញ)
លេខទូរសព្ទ៖ ០១២ ៩៥៧ ៦៨៤/០១១ ៦៦៦ ២២៦
៣. វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ (ភ្នំពេញ)
លេខទូរសព្ទ៖ ០១២ ៧៦៦ ៤៨៨/០១៦ ៥២៨ ៨០០
៤. វិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ (ភ្នំពេញ)
លេខទូរសព្ទ៖ ០៦៩ ៦០៦ ៥៧២/០១២ ៨៥៣ ០៣០
៥. វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ (ភ្នំពេញ)
លេខទូរសព្ទ៖ ០១១ ២៩៨ ៤៥៦/០១០ ៣៤៩ ៦៦៦
៦. វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្ម (ភ្នំពេញ)
លេខទូរសព្ទ៖ ០៩៩ ៤៤៤ ៣៣០/០១០ ៩០១ ១៧៧
៧. វិទ្យាស្ថានអភិវឌ្ឍន៍មុខជំនាញកម្ពុជា-ថៃ (ភ្នំពេញ)
លេខទូរសព្ទ៖ ០៩២ ៨២៧ ០៨៨/០១៦ ៧៤៩ ០៧០
៨. វិទ្យាស្ថានបច្ចេកទេស ហ្ស៊ី វ៉េ សេ (ភ្នំពេញ)
លេខទូរសព្ទ៖ ០១២ ៤៩៩ ៩៥៩/០៩៥ ៨០៦ ១៧៤
៩. វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ
លេខទូរសព្ទ៖ ០១៦ ៧៣៣ ៣០៤/០១២ ៩៥៦ ០១២
១០. វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង
លេខទូរសព្ទ៖ ០១២ ២៦៧ ៦៧៩/០៨៨ ៩៥៣២ ៣៣៣
១១. វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនញ៉សាន (ក្រចេះ)
លេខទូរសព្ទ៖ ០៩៧ ៧៦៧ ៤០០១/០៩៧ ៧៨៧ ០០០៩
១២. វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនសៀមរាប
លេខទូរសព្ទ៖ ០១២ ៩១៨ ១៦៧/០៩៧ ៧០០ ៧៧៩៤
១៣. វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ (សៀមរាប)
លេខទូរសព្ទ៖ ០១៧ ៦៧៤ ៤៤៦/០៩៣ ៤៩៩ ៧៧៧
១៤.វិទ្យាស្ថានពហុបច្ចេកទេសខេត្តពោធិ៍សាត់
លេខទូរសព្ទ៖ ០១២ ៣៣២ ៨៧៦/០១១ ៩៩៥ ០៣៦
១៥. វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនបាត់ដំបង
លេខទូរសព្ទ៖ ០១៧ ៤៨០ ៧៦២/០៨៦ ៨៧៩ ២៩២
១៦. វិទ្យាស្ថានបច្ចេកវិទ្យាបាត់ដំបង
លេខទូរសព្ទ៖ ០១២ ២៩០ ០៨៦/០១៦ ៥២២ ២០៦
១៧. វិទ្យាស្ថានជាតិវិជ្ជាជីវៈបាត់ដំបង
លេខទូរសព្ទ៖ ០៦៩ ៥៨៥ ៨៥៥/០១២ ៨២២ ៤៩៥
១៨. វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះសីហនុ
លេខទូរសព្ទ៖ ០៩២ ៨៨៤ ៨២៨/០១៥ ៨៨៤ ៨២៨
១៩. វិទ្យាស្ថានពហុបច្ចេកទេសមិត្តភាពកម្ពុជា ចិនខេត្តព្រះសីហនុ
លេខទូរសព្ទ៖ ០១២ ២៦១ ២៤២/០១៦ ៦៣៣ ៣៦៧
២០. វិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនកំពត
លេខទូរសព្ទ៖ ០១២ ២៨៩ ៩៩២/០៩៣ ៥៣៦ ៤៦៤
២១. វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម
លេខទូរសព្ទ៖ ០១៧ ៩១៤ ៥៤៧/០៩៧ ៣៨២ ៨២៦១
២២. វិទ្យាស្ថានពហុបច្ចេកទេសខេត្តបន្ទាយមានជ័យ
លេខទូរសព្ទ៖ ០៧៧ ៩៦៩ ៨៥៨/០១៧ ៧៥០ ៥០៥
២៣. វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ធំ
លេខទូរសព្ទ៖ ០១២ ២៥៩ ៦៤៩/០៩៦ ៩៤៣ ២៧៩៦
២៤. វិទ្យាស្ថានជាតិពហុបច្ចេកទេសតេជោសែន (ខេត្តកណ្តាល)
លេខទូរសព្ទ៖ ០១០ ៣៣៧ ១៦៦/០៩២ ៧៣៥ ២៦៣
២៥. វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ស្ពឺ
លេខទូរសព្ទ៖ ០៨១ ៩៩៥ ៩៥២/០៦៧ ៤០៤ ៣៤៣
២៦. វិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង
លេខទូរសព្ទ៖ ០៨១ ២៥១ ៦៦៦/០៩៧ ៨៣៨ ៨៨៦៥
២៧. វិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ឆ្នាំង
លេខទូរសព្ទ៖ ០៩៨ ៤៧៤ ៣៤១/០៩៧ ២៦៩ ៥៧១៣
២៨. វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រៃវែង
លេខទូរសព្ទ៖ ០១២ ៧៧២ ០៣៧/០៩៦ ៧៥៧ ៧៧១៤
២៩. វិទ្យាស្ថានពហុបច្ចេកទេសខេត្តព្រះវិហារ
លេខទូរសព្ទ៖ ០១២ ៩៨១ ២៧៥/០៩៧ ៨៤៣ ០៧៧៧
៣០. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈព្រះវិហារ-យ៉ាឡាយ
លេខទូរសព្ទ៖ ០៦៨ ២៣៣ ៣០៣
៣១. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តស្ទឹងត្រែង
លេខទូរសព្ទ៖ ០៩៧ ៨៨៨ ៦៦៦២/០៨៨ ៥៨៥ ៥៦៥៦
៣២. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តរតនគិរី
លេខទូរសព្ទ៖ ០១២ ៣៨៧ ៦៦៤/០៨៩ ៨៤២ ៧៣៥
៣៣. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តប៉ៃលិន
លេខទូរសព្ទ៖ ០៩៧ ៥៥៥ ៦៦២៧/០៨៦ ២៤៤ ៩០១
៣៤. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តឧត្តរមានជ័យ
លេខទូរសព្ទ៖ ០១៧ ៥១៤ ៧១៤/០៩២ ៦២៨ ៨២៨
៣៥. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តមណ្ឌលគិរី
លេខទូរសព្ទ៖ ០១២ ៣១៣ ៣៦២/០១១ ៩៨០ ៨១៨
៣៦. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តត្បូងឃ្មុំ
លេខទូរសព្ទ៖ ០១២ ៦៧៥ ៦២៨/០៧០ ២៦៩ ២៩២
៣៧. មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកែប
លេខទូរសព្ទ៖ ០៩២ ៦៩៣ ២៦៩/០៩៧ ៩៧១ ៩១៦៨

**ព័ត៌មានបន្ថែម៖**
សូមទំនាក់ទំនង
**១២៨៦ / ១២៩៧**
ស្កេនទីនេះ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ខ. ឱកាសទទួលបានការប្រឹក្សាយោបល់ និងឱកាសការងារ

ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គឺជាទីភ្នាក់ងារសេវាសាធារណៈ ដែលផ្តល់ជំនួយក្នុងការស្វែងរកការងារធ្វើ តាមរយៈមជ្ឈមណ្ឌលការងារចំនួន ១៤កន្លែង និងមជ្ឈមណ្ឌលផ្តល់ព័ត៌មានចល័តចំនួន ៧កន្លែង តាមរយៈគេហទំព័រការងារ www.nea.gov.kh និងតាមកម្មវិធីទូរសព្ទឈ្មោះ NEA Job Search។ ទ.ជ.ម.ក. ផ្តល់ព័ត៌មានអំពីការងារ ការផ្តល់ប្រឹក្សាការងារ និងការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈសម្រាប់យុវជន សិស្ស-និស្សិត និងអ្នកស្វែងរកការងារធ្វើនៅទូទាំងប្រទេសដោយមិនគិតថ្លៃសេវា។ ដើម្បីអាចត្រៀមលក្ខណសម្បត្តិឱ្យបានល្អដើម្បីចូលទីផ្សារការងារ អ្នកស្វែងរកការងារត្រូវស្វែងយល់អំពីគន្លឹះមួយចំនួនមុនពេលដាក់ពាក្យរកការងារ ដែលចំណេះដឹងទាំងអស់នេះ ទីភ្នាក់ងារជាតិមុខរបរ និងការងារ តែងតែផ្តល់ប្រឹក្សាយោបល់ និងផ្តល់វគ្គបណ្តុះបណ្តាលដល់អ្នកស្វែងរកការងារជាបន្តបន្ទាប់ ដោយឥតគិតថ្លៃ។ ទន្ទឹមនឹងនេះ ទ.ជ.ម.ក. សហការយ៉ាងជិតស្និទ្ធជាមួយនិយោជក ដើម្បីផ្គូផ្គងតម្រូវការការងារជាមួយនឹងជំនាញរបស់អ្នកស្វែងរកការងារ និងរៀបចំពិព័រណ៌ការងារ ដើម្បីផ្តល់ឱកាសការងារជាច្រើនដល់យុវជន។

# ការស្វែងយល់អំពីខ្លួនឯង មុននឹងដាក់ពាក្យរកការងារ និងសម្រេចចិត្តទទួលការងារ




## គន្លឹះមួយចំនួនមុនពេលដាក់ពាក្យរកការងារ




ទ.ជ.ម.ក. បានរៀបចំចងក្រង និងបោះពុម្ពផ្សព្វផ្សាយនូវសៀវភៅ **«ការស្វែងយល់ពីខ្លួនឯង៖ កម្រងសំណួរសម្រាប់ការរៀបចំផែនការសិក្សា និងការជ្រើសរើសការងារនិងអាជីព»** ជាស្នាដៃសម្រាប់បំផុសគំនិតរៀបចំមាគ៌ាជីវិតអាជីព សម្រាប់អនាគតដល់សិស្ស និស្សិត និងអ្នកកំពុងស្វែងរកការងារ។ សិស្ស និស្សិត និងអ្នកកំពុងស្វែងរកការងារ អាចស្វែងរកសៀវភៅនេះបាននៅលើគេហទំព័ររបស់ ទ.ជ.ម.ក. ដើម្បីអាន និងស្វែងយល់បន្ថែម ឬក៏អាច មកដល់ទីតាំងនៅគ្រប់មជ្ឈមណ្ឌលការងារ ដើម្បីធ្វើតេស្ត និងទទួលបានលទ្ធផល ព្រមទាំងអាចទទួលបានសេវាប្រឹក្សាផ្ទាល់ជាមួយអ្នកជំនាញប្រឹក្សាអាជីពក្នុងការរៀបចំផែនការអាជីព និងការសិក្សារបស់ខ្លួនប្រកប សដោយភាពជោគជ័យ។




ផ្សព្វផ្សាយព័ត៌មាន
ជ្រើសរើសបុគ្គលិក
ការផ្គូផ្គងការងារ
ចុះឈ្មោះ
ស្វែងរកការងារធ្វើ
សម្ភាសការងារ
NEA
វេទិកាការងារ
ព័ត៌មាន
ទីផ្សារការងារ
វគ្គបណ្តុះបណ្តាល
ជំនាញទន់
ការណែនាំ
និងប្រឹក្សាយោបល់
អាជីព និងការងារ
ការផ្តល់សេវាជួយស្វែងរកការងារធ្វើជូនប្រជាពលរដ្ឋ ជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល!


National Caree
វេទិកាការងារ
ប្រចាំខែ
ពិព័រណ៍ការងារ
និងមគ្គុទេសន៍អាជីព
ពិព័រណ៍ការងារ
និងផលិតភាពជាតិ
26-27 ខែតុលា ឆ្នាំ2024


ទីតាំងមជ្ឈមណ្ឌលការងាររបស់
ទីភ្នាក់ងារជាតិមុខរបរ និងការងារ នៅតាមរាជធានី-ខេត្ត
ម.ក រាជធានីភ្នំពេញ
023 633 6002 / 016 786 655
ម.ក ខេត្តសៀមរាប
063 210 277 / 016 536 655
ម.ក ខេត្តបាត់ដំបង
053 733 111 / 016 926 655
ម.ក ខេត្តកំពង់ចាម
042 210 277 / 016 656 655
ម.ក ខេត្តកំពង់ធំ
062 210 277 / 016 836 655
ម.ក ខេត្តព្រះសីហនុ
081 856 655
ម.ក ខេត្តតាកែវ
016 676 655
ម.ក ខេត្តពោធិ៍សាត់
052 740 277 / 010 706 655
ម.ក ខេត្តកំពត
033 210 277 / 016 506 655
ម.ក ខេត្តបន្ទាយមានជ័យ
054 210 277 / 016 326 655
ម.ក ខេត្តព្រៃវែង
043 210 277 / 081 786 655
ម.ក ខេត្តស្ទឹងត្រែង
074 212 277 / 010 746 655
ម.ក ខេត្តស្វាយរៀង
044 715 277 / 010 746 655
ម.ក ខេត្តកោះកុង
010 236 655
មជ្ឈមណ្ឌលការងារចល័ត
Mobile Job Center
មជ្ឈមណ្ឌលការងារ នៅផ្សារទំនើប
AEON Mall សែនសុខ (ជាន់ទី2)
012 906 664 / 086 860 066
ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់
023 633 6002 / 077 232 378 / 016 786 655
069 31 66 55 (មជ្ឈមណ្ឌលការងារ នៅផ្សារទំនើប AEON Mall សែនសុខ)
www.nea.gov.kh
info@nea.gov.kh
ការងារខ្ញុំ-My Job (NEA)
/neakhmer
NEA-ឱកាសការងារ
/NationalEplоymentAgency
ទាញយកកម្មវិធី
ស្វែងរកការងារ
តាមទូរស័ព្ទដៃ
ឥឡូវនេះ!
SCAN ME!
NEA Job Search App
App Store
Google Play

# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**គាំទ្រការបោះពុម្ពដោយ**

KB PRASAC Bank

DEY DECENT EMPLOYMENT FOR YOUTH IN CAMBODIA

មិត្តយើង Mett Yeung ២៧


Hotline: 1297/1286

www.mlvt.gov.kh

www.facebook/mlvt.gov.kh

t.me/molvtkhmer

អាសយដ្ឋានៈ អាគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី ខណ្ឌទួលគោក រាជធានីភ្នំពេញ